ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN

លេខទី ១០ ត្រីមាសទី១ ឆ្នាំ ២០១៩ ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម A PUBLICATION OF THE DEPARTMENT OF AGRICULTURAL EXTENSION

Facebook : នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម / Department of Agricultural Extension



# បទពិសោធន៍ជោគជ័យលើការអនុវត្តប្រព័ន្ធកសិកម្មចម្រុះល្អ

របស់កសិករ ឈាវ ហុង រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប

ព្រឹត្តប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រងនូវរាល់បទពិសោធន៍ជោគជ័យផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់របស់កសិករ ក៏ដូចជាសហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តការងារមកចងក្រង និងធ្វើការផ្សព្វផ្សាយជូនដល់ប្រជាកសិករ សហគមន៍និងដៃគូពាក់ព័ន្ធផ្សេងទៀតដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ការប្រកបរបរពាក់ព័ន្ធនឹងវិស័យកសិកម្ម។

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះដែរ បានលើកយកបទពិសោធន៍ជោគជ័យរបស់កសិករឈ្មោះ **ឈាវ ហុង** រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូទ្រនិគម ខេត្តសៀមរាប ជាកសិករឆ្នើម ធ្លាប់ទទួលបានទទួលជ័យលាភី លើការធ្វើកសិកម្មតាមបែបប្រព័ន្ធកសិកម្មចម្រុះមកបង្ហាញជូនដូចខាងក្រោម៖

## ១- អំពីប្រវត្តិ

កសិករឈ្មោះ **ឈាវ ហុង** មានអាយុ៥៩ឆ្នាំ រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប មានសមាជិកគ្រួសារចំនួន៧នាក់ និងមានមុខរបរធ្វើកសិកម្មចាប់តាំងពីឆ្នាំ២០០០ មកម្ល៉េះ។

កសិករឈ្មោះ **ឈាវ ហុង** បានរៀបរាប់ថា ការធ្វើកសិកម្ម ពេលចាប់ផ្តើមដំបូងហាក់មិនទទួលបានភាពជោគជ័យប៉ុន្មានទេ ដោយមិនមានបច្ចេកទេស។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០០០ មក គាត់តែងទទួលបាននូវការបណ្តុះបណ្តាលជាហូរហែ តាមរយៈអង្គការ គម្រោងអភិវឌ្ឍន៍ផ្សេងៗ ពិសេសមន្ត្រីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ធ្វើឱ្យមុខរបរកសិកម្មរបស់គាត់ទទួលបានភាពជោគជ័យ និងធ្វើឱ្យជីវភាពរស់នៅរបស់គ្រួសារគាត់ តាំងពីគ្មានអ្វីសោះ រហូតមកដល់ពេលនេះគាត់មានជីវភាពធូរធារ មានលទ្ធភាពសាងសង់ផ្ទះ ទិញរថយន្ត បញ្ជូនកូនទៅរៀននៅមហាវិទ្យាល័យ និងជាពិសេសក្រុមគ្រួសារគាត់ អាចរស់នៅជួបជុំគ្នា ដោយមិនចាំចាច់ធ្វើចំណាកស្រុក ។



ផ្ទះកសិករឈ្មោះ **ឈាវ ហុង** នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប

ដូចជាដំណាំស្វាយ និងដំណាំរួមផ្សំជាច្រើនមុខទៀត។



ចម្ការស្វាយរបស់កសិករ ឈាវ ហុង



សកម្មភាពនៃការដាំដំណាំរួមផ្សំរបស់
កសិករ ឈាវ ហុង

## ៣. អំពីផលិតកម្ម

កសិករ ឈាវ ហុង បានរៀបរាប់ឱ្យដឹងទៀតថា ក្នុងការធ្វើផលិតកម្មរបស់គាត់មានដូចជា ការផលិតពូជផ្ការំដួល



ការចិញ្ចឹមត្រី ការផលិតជីកំប៉ុស្ត ការដាំដំណាំត្រសក់ស្រូវ ការធ្វើផ្សិតចំបើង និងដំណាំរួមផ្សំជាច្រើនទៀតមានដូចជាដំណាំក្រូចឆ្មា ល្ហុង ម្ទេស ..។



សកម្មភាពនៃការផ្តល់ចំណីឱ្យត្រីរបស់កសិករ ឈាវ ហុង



សកម្មភាពនៃការផលិតជីកំប៉ុស្តរបស់កសិករ ឈាវ ហុង
និងសមាជិកគ្រួសារ



សកម្មភាពនៃការប្រមូលផលដំណាំត្រសក់ស្រូវរបស់
កសិករ ឈាវ ហុង



ទិដ្ឋភាពផ្សិតចំបើងក្នុងរោងផលិតរបស់កសិករ ឈាវ ហ៊ុង

## ៤. ការវិភាគសេដ្ឋកិច្ច ក្នុងការអនុវត្តប្រព័ន្ធកសិកម្មចម្រុះ

កសិករ ឈាវ ហ៊ុង បានរៀបរាប់ប្រាប់ថា ក្នុងការធ្វើប្រព័ន្ធកសិកម្មចម្រុះនេះ ចំពោះដំណាំស្រូវគាត់បានចំណាយថវិកាអស់ចំនួន ៣,៦៧០,០០០ រៀល ក្នុងនោះមាន ការចំណាយទៅលើការភ្ជួរដីអស់ ៥០០,០០០ រៀល ថ្នាំស្មៅអស់ ២២០,០០០រៀល ជីសរីរាង្គ១០កំប៉ុងអស់ ៧៥០,០០០រៀល ជីអ៊ុយរ៉េចំនួន៤ការ៉ុងអស់ ៤០០,០០០រៀល ជីកំប៉ុស្តទឹកអស់ ៨០,០០០ រៀល ថ្លៃច្រូតអស់ ១,០៥០,០០០ រៀល ថ្លៃបោក និងដឹកអស់២២០,០០០រៀល ថ្លៃអុំសម្អាតគ្រាប់អស់៣០០,០០០ រៀល ផ្សេងៗអស់១៥០,០០០រៀល។ រីឯចំណូល ដែលគាត់ទទួលបាន ពីផលិតកម្មពូជស្រូវរបស់គាត់បានចំនួន ៣៣,៧៥០,០០០រៀល និងពេលដែលគាត់យកការចំណាយ ទៅដកជាមួយចំណូល ឃើញថា ក្នុងផលិតកម្មផលិតពូជស្រូវរបស់គាត់ ទទួលបានផលចំណេញចំនួន ៣០,០៨០,០០០ រៀល។

នៅពេលដែលក្រុមការងារ សួរគាត់អំពីការវិភាគសេដ្ឋកិច្ចទៅលើការដាំដំណាំរួមផ្សំវិញ តើយ៉ាងណាដែរ? កសិករ ឈាវ ហ៊ុង គាត់មានប្រសាសន៍ថា គាត់បានធ្វើការចំណាយអស់ថវិកាចំនួន១១,៥០៦,០០០ រៀល ក្នុងនោះមានដំណាំត្រសក់ស្រូវអស់ចំនួន ៥,៧៣៥,០០០ រៀល ដំណាំឪឡឹកអស់ ១,១៩៥,០០០រៀល ដំណាំពោតអស់ចំនួន២៣៨,០០០រៀល ដំណាំត្រប់អស់ចំនួន៣៣៣,០០០ រៀល ដំណាំសណ្តែកកួរអស់ ២៣០,០០០ រៀល ដំណាំស្វាយអស់ចំនួន២៣០,០០០រៀល ដំណាំននោងអស់ចំនួន ២០,០០០រៀល ចំណាយលើការងារចិញ្ចឹមត្រី អស់ចំនួន ១,៣០០,០០០រៀល និងការចំណាយលើការងារបណ្តុះផ្សិតអស់ចំនួន២,៤៥៥,០០០រៀលនៅក្នុង១ខែ ហើយទទួលបានប្រាក់ចំណូលពីការធ្វើប្រព័ន្ធកសិកម្មចម្រុះនេះមកវិញចំនួន ៣៥,៩០៦,០០០ រៀល និងទទួលបានប្រាក់ចំណេញចំនួន ២៤,៤០០,០០០រៀល។

កសិករ ឈាវ ហ៊ុង បានបន្តទៀតថា ក្រោយពីបានធ្វើការទូទាត់រវាងចំណាយ និងចំណូល ពីការធ្វើប្រព័ន្ធកសិកម្មចម្រុះខាងលើ គាត់ទទួលបានប្រាក់ចំណេញចំនួន៥៤,៤៨០,០០០រៀល ។



ផលិតផលឪឡឹករបស់កសិករ ឈាវ ហ៊ុង ត្រូវបានដាក់លក់



សកម្មភាពនៃការចែករំលែកបទពិសោធន៍របស់កសិករ ឈាវ ហ៊ុង ជូនដល់កសិករដទៃ

**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប
- កសិករ ឈាវ ហ៊ុង រស់នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០៨៥ ៨៥១៩៧២






ក្រុមគ្រួសារកសិករឈ្មោះ ឈាវ ហ៊ុង នៅភូមិសំរោងត្បូង ឃុំសំរោង ស្រុកសូត្រនិគម ខេត្តសៀមរាប

## ២. អំពីការបែងចែកដីសម្រាប់ធ្វើកសិកម្ម

កសិករ ឈាវ ហ៊ុង បានរៀបរាប់ប្រាប់ថា គាត់មានផ្ទៃដីសម្រាប់ធ្វើកសិកម្មទំហំ ៦ហិកតា ដោយបានបែងចែកផ្ទៃដីសម្រាប់ធ្វើស្រែចំនួន ៤.៥ហិកតា ផ្ទៃដីសម្រាប់ដាំបន្លែចំនួន ៧៤អា ផ្ទៃដីសម្រាប់ជីកស្រះទឹក ៣ កន្លែងដែលស្រះទី១ មានទំហំ ( ទទឹង ៨ ម៉ែត្រ x បណ្ដោយ១០ ម៉ែត្រ x ជម្រៅ ៥ម៉ែត្រ ) ( ស្រះទី២ ទទឹង ៨ ម៉ែត្រ x បណ្ដោយ១២ ម៉ែត្រ x ជម្រៅ ៥ម៉ែត្រ ) និងស្រះទី៣ (មានទទឹង ១២ ម៉ែត្រx បណ្ដោយ ៤០ ម៉ែត្រ ជម្រៅ ៥ ម៉ែត្រ) ។

កសិករ ឈាវ ហ៊ុង បានបន្តទៀតថា ស្រះទឹកនេះមានតួនាទីសំខាន់ពីរ ទីមួយគឺសម្រាប់យកមកស្រោចស្រពដំណាំបន្លែ និងដំណាំស្រូវ ទីពីរ សម្រាប់ទាក់ទាញត្រីពីធម្មជាតិពិសេសអាចចិញ្ចឹមត្រីគ្រប់ប្រភេទបានទៀតផង ។



សកម្មភាពប្រមូលផលស្រូវរបស់កសិករ ឈាវ ហ៊ុង និងសមាជិកគ្រួសារ



សកម្មភាពនៃការដាំដំណាំបន្លែរបស់កសិករ ឈាវ ហ៊ុង



ស្រះចិញ្ចឹមត្រីរបស់កសិករ ឈាវ ហ៊ុង

កសិករ ឈាវ ហ៊ុង បានរៀបរាប់បន្តទៀតថា ក្រៅពីដីសម្រាប់ធ្វើស្រែ ដីសម្រាប់ដាំដំណាំ និងដីសម្រាប់ជីកស្រះត្រី គាត់ក៏មានដីសម្រាប់ធ្វើកសិកម្មចម្រុះផងដែរ ក្នុងនោះមាន